# ដើម្បីសុខភាពមាតា និងទារក



នៅប្រទេសកម្ពុជា កង្វះខាតឆ្មប គឺជាបញ្ហាចោទមួយសម្រាប់វិស័យសុខាភិបាល ជាពិសេសនៅតំបន់ជនបទ។ ដោយសារតែកង្វះខាតនេះ ឆ្មបមួយចំនួនដែលត្រូវបានចាត់បញ្ជូនឲ្យទៅធ្វើការនៅតាមមណ្ឌលសុខភាព នៅមិនទាន់បានទទួលនូវការបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រាន់ ហេតុនេះហើយសមត្ថភាពរបស់គាត់នៅមានកម្រិតនៅឡើយ។

ឆ្លើយតបនឹងបញ្ហានេះ JICA បានផ្តល់នូវវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល ក្នុងគោលបំណងពង្រឹងសេវាថែទាំផ្នែកសម្ភពប្រកបដោយគុណភាពខ្ពស់នៅទូទាំងប្រទេសកម្ពុជា។ គ្រូបង្គោលឆ្មបដើរតួនាទីយ៉ាងសំខាន់ជាមន្ត្រីសុខាភិបាលគំរូផ្នែកសម្ភព ក្នុងការផ្តល់នូវការថែទាំប្រកបដោយសុវត្ថិភាព និងក្តីស្រឡាញ់ដល់មាតា និងទារក។ លើសពីនេះទៅទៀត គាត់គឺជាគ្រូកម្មសិក្សា ធ្វើការអនុវត្តបង្ហាត់បង្ហាញពី "អ្វីជាការថែទាំរបស់ឆ្មប" ដែលគាត់បានទទួលតាមរយៈការបណ្តុះបណ្តាលទៅដល់ឆ្មបផ្សេងៗទៀតនៅក្នុងតំបន់ជុំវិញ ដើម្បីធ្វើឲ្យវិស័យសុខាភិបាលផ្នែកសម្ភពមានភាពប្រសើរឡើង។